# ធម្មទេសនារបស់លោកអភិបាលអូលីវីយេ
# អភិបូជាប្រជុំជាមួយប្រធានបុព្វជិតបុព្វជិតា
# ថ្ងៃទី០៧ មករា ២០១៧

អត្ថបទទី១៖ ១យហ ៥,១៤-២១
ដំណឹងល្អ៖ យហ ២,១-១១

បងប្រុសបងស្រីជាទីស្រឡាញ់!

ថ្ងៃនេះ យើងបានជួមជុំគ្នាជាមួយអ្នកណែនាំក្រុមបុព្វជិតបុព្វជិតានៅប្រទេសកម្ពុជា ព្រះជាម្ចាស់ណែនាំឲ្យយើងភ្ញាក់ស្មារតីសម្រាប់ឆ្នាំថ្មីនេះ។ នៅក្នុងអត្ថបទទីមួយ "**ប្រសិនបើយើងទូលសុំអ្វីស្របតាមព្រះហឫទ័យរបស់ព្រះអង្គ នោះទ្រង់នឹងព្រះសណ្ដាប់យើងជាមិនខាន**" យើងទៅដល់គោលដៅនៃជីវិតរបស់យើង។ ណែនាំឲ្យយើងគិតអំពីមូលហេតុដែលយើងមកធ្វើការនៅប្រទេសកម្ពុជា សកម្មភាពដែលយើងបានបង្កើតពីមួយឆ្នាំទៅមួយឆ្នាំតាមក្រុមគ្រួសារនីមួយៗ យើងយល់ថាយើងអាចធ្វើបានដោយសារយើងធ្វើតាមព្រះហឫទ័យរបស់ព្រះជាម្ចាស់ មានន័យថាយើងចូលរួមនៅក្នុងជីវិតនៃព្រះសហគមន៍នៅទីនេះ ដើម្បីធ្វើជាធ្លុងតែមួយជាមួយព្រះសហគមន៍ប្រទេសកម្ពុជាដោយអធិដ្ឋាន ដោយស្ដាប់ព្រះបន្ទូលរបស់ព្រះជាម្ចាស់ដែលបំភ្លឺយើង នោះយើងអាចទទួលពន្លឺថ្មីដើម្បីរស់នៅតាមការត្រាស់ហៅនៃក្រុមគ្រួសារនីមួយៗ ដោយស្របតាមព្រះហឫទ័យរបស់ព្រះជាម្ចាស់។ មានក្រុមថ្មីៗច្រើនបានសុំមកធ្វើការនៅប្រទេសកម្ពុជា ដោយគេនិយាយថាគេបានសម្រេចចិត្តហើយថានឹងមកធញរើការនៅប្រទេសកម្ពុជា ខ្ញុំសួរថាតើបានសម្រេចតាមព្រះហឫទ័យរបស់ព្រះជាម្ចាស់ឬតាមព្រះវិញ្ញាណដ៏វិសុទ្ធឬនៅ? យើងមិនអាចសម្រេចចិត្តតែម្ខាងទេ ផ្ទុយទៅវិញយើងត្រូវការស្ដាប់សេចក្ដីត្រូវការនៃព្រះសហគមន៍នៅប្រទេសកម្ពុជា ក្រោយមកយើងចូលគ្នាអ្វីដែលយើងបានសម្រេចចិត្ត អ្វីដែលជាសេចក្ដីត្រូវការនៅទីនេះ ចូលគ្នាហើយដើម្បីរកឃើញព្រះហឫទ័យរបស់ព្រះជាម្ចាស់ពិតមែន។ ថ្ងៃនេះយើងអរព្រះគុណព្រះជាម្ចាស់ ដែលបានណែនាំឲ្យយើងចូលនៅក្នុងមូលដ្ឋានគ្រឹះនៃជីវិតរបស់យើងជាបុព្វជិតបុព្វជិតា គឺធ្វើតាមព្រះហឫទ័យរបស់ព្រះជាម្ចាស់។ នៅពេលយើងចង់បង្កើតកន្លែងថ្មី ទីតាំងថ្មី យើងត្រូវការស្របតាមសេចក្ដីត្រូវការរបស់ព្រះសហគមន៍ ដើម្បីចូលគ្នារកឃើញព្រះហឫទ័យរបស់ព្រះជាម្ចាស់។ តួនាទីរបស់យើង គឺយើងមិនមកបម្រើក្រុមរបស់យើងទេ គឺយើងមកបម្រើព្រះសហគមន៍នៅទីនេះ។ ព្រះសហគមន៍មានវត្តមានពីយូរឆ្នាំហើយ យើងមកទីនេះដើម្បីបម្រើតាមតួនាទីរបស់យើងក្នុងក្រុមគ្រួសារនីមួយៗ តាមកម្លាំង តាមសកម្មភាពដែលយើងអាចធ្វើបាន។ យើងត្រូវអង្គុយដើម្បីស្ដាប់សម្លេងព្រះសហគមន៍ ដើម្បីចាប់ផ្ដើមរកឃើញព្រះហឫទ័យរបស់ព្រះជាម្ចាស់ ដោយធ្វើជាធ្លុងតែមួយជាមួយព្រះសហគមន៍ នៅក្នុងការអធិដ្ឋាន និងនៅក្នុងការស្ដាប់ព្រះបន្ទូលរបស់ព្រះជាម្ចាស់។

ក្នុងអត្ថបទទីមួយ "**យើងដឹងថាយើងកើតមកពីព្រះជាម្ចាស់**" នេះជាជីវិតរបស់យើងតែម្តង ជាព្រះជាម្ចាស់ដែលបានជ្រើសរើស ជាព្រះជាម្ចាស់ដែលបានបង្កើតយើង ជាព្រះជាម្ចាស់ដែលបានចាត់យើងឲ្យមក ជាព្រះជាម្ចាស់ដែលណែនាំយើង ជាព្រះជាម្ចាស់ដែលធ្វើដំណើរជាមួយយើង។ នេះជាសញ្ញាមួយយ៉ាងពិសេស ដោយសារជីវិតជាអ្នកបួសជាសញ្ញាមួយពិសេសក្នុងសង្គមយើងបច្ចុប្បន្ននេះ យើងនៅក្នុងលោកីយ៍ប៉ុន្តែយើងមិនមែនមកពីលោកីយ៍ទេ ដោយសារព្រះជាម្ចាស់បានបង្កើតយើង។ នេះជាកម្លាំងជាពន្លឺរបស់យើង ដើម្បីដឹងថាជីវិតរបស់យើងទៅជាសញ្ញាសម្គាល់មួយយ៉ាងពិសេសសម្រាប់បងប្អូនឯទៀតៗដែលមិនដែលស្គាល់ព្រះជាម្ចាស់ ដែលមិនស្គាល់ព្រះសហគមន៍ ប៉ុន្តែយើងដឹងថាជីវិតរបស់យើងទៅជាសញ្ញាមួយយ៉ាងអស្ចារ្យ ដោយសារយើងមកពីព្រះជាម្ចាស់តែម្តង។ យើងមើលរបៀបព្រះនាងម៉ារីក្នុងអត្ថបទព្រះគម្ពីរ "**មាតាព្រះយេស៊ូនៅទីនេះ**" នេះជាតួនាទីរបស់យើងឲ្យយើងនៅទីនេះ ឲ្យវត្តមានរបស់យើងទៅជាសញ្ញាសម្គាល់នៃវត្តមានរបស់ព្រះជាម្ចាស់។ លោកយ៉ូហាន ដែលទទួលពន្លឺពីព្រះវិញ្ញាណដ៏វិសុទ្ធចង់បង្ហាញថា មាតាព្រះយេស៊ូនៅទីនេះ។ ដូចពេលព្រះយេស៊ូបានជ្រើសរើសក្រុមសាវ័ក ក្រុមសាវ័កបាននៅជាមួយព្រះយេស៊ូ។ ដូច្នេះជីវិតរបស់យើងជាបុព្វជិតបុព្វជិតា ដូចព្រះនាងម៉ារីយើងនៅទីនេះវត្តមានរបស់យើងមានអត្ថន័យលើសពីស្នាដៃ សកម្មភាពរបស់យើងច្រើនណាស់។ របៀបដែលយើងរស់នៅ នៅក្នុងសេចក្តីស្រឡាញ់ នៅក្នុងភាពក្រីក្រ នៅក្នុងការលះបង់ នេះជាអត្ថន័យយ៉ាងជ្រៅសម្រាប់បងប្អូនឯទៀត។ ព្រះនាងម៉ារីបាននិយាយទៅអ្នកបម្រើថា "**បើលោកប្រាប់ឲ្យធ្វើអ្វីចូរធ្វើតាមលោកទៅ**" យើងត្រូវតែធ្វើតាមព្រះហឫទ័យព្រះជាម្ចាស់។ ប៉ុន្តែមិនមែនព្រះនាងម៉ារីដែលធ្វើទេ គឺព្រះនាងម៉ារីជាអ្នកណែនាំយើងទុកឲ្យព្រះយេស៊ូដែលធ្វើនៅក្នុងជីវិតរបស់យើង។ យើងដឹងថាមិនមែនយើងដែលធ្វើទេគឺព្រះយេស៊ូដែលធ្វើបន្តិចម្តងៗយើងអាចនិយាយដូចសន្តប៉ូលថា "**មិនមែនខ្ញុំដែលរស់នៅ គឺព្រះយេស៊ូដែលរស់នៅក្នុងខ្ញុំ**"។

ព្រះយេស៊ូបានសម្តែងសេរីរុងរឿងរបស់ព្រះជាម្ចាស់លើកទីមួយ បន្ទាប់ពីព្រះយេស៊ូចេញពីភូមិណាសារ៉ែតទៅប្រកាសដំណឹងល្អ ព្រះអង្គបានជ្រើសរើសមង្គលការ។ ឆ្នាំនេះយើងចូលនៅក្នុងឆ្នាំគ្រួសារ ព្រះយេស៊ូបានជ្រើសរើសមង្គលការ ដែលជាពេលវេលាដែលប្តីប្រពន្ធបង្កើតគ្រួសារថ្មី។ ព្រះយេស៊ូបានរើសក្រុមគ្រួសារជាអាទិភាព ដើម្បីសម្តែងអំពីឋានៈរបស់ព្រះអង្គ យើងយល់ថាមង្គលការជាអំណរសប្បាយ។ កន្លែងណាមានបុព្វជិតបុព្វជិតា កន្លែងនោះមានអំណរសប្បាយ ជាកន្លែងដែលព្រះយេស៊ូបានជ្រើសរើសដើម្បីសម្តែងសេរីរុងរឿងរបស់ព្រះអង្គ នៅក្នុងមង្គលការដើម្បីបង្ហាញថាក្រុមគ្រួសារដែលចេះស្រឡាញ់គ្នាទៅវិញទៅមក ជាព្រះសហគមន៍យ៉ាងតូចមួយអាចបំភ្លឺសង្គមទាំងមូល។

យើងបន្តអធិដ្ឋាន ដើម្បីឲ្យយើងរួមគ្នាធ្វើតាមព្រះហឫទ័យរបស់ព្រះជាម្ចាស់ជានិច្ច ដោយដឹងថាយើងកើតពីព្រះជាម្ចាស់ វត្តមានរបស់យើងមានន័យដើម្បីឲ្យអំណរសប្បាយរបស់ព្រះគ្រីស្ដយាងចូលនៅគ្រប់ទីកន្លែងតាមរយៈជីវិតរបស់យើងជាបុព្វជិតបុព្វជិតា បម្រើព្រះសហគមន៍នៅប្រទេសកម្ពុជា។ សូមអរព្រះគុណព្រព្រះជាម្ចាស់ និងសូមទូលអង្វរព្រះវិញ្ញាណដ៏វិសុទ្ធបំភ្លឺយើង ឲ្យឆ្នាំយើងអាចទៅជាធ្លុងតែមួយរវាងគ្នានឹងគ្នា ធ្លុងតែមួយជាមួយព្រះសហគមន៍ដែលយើងបម្រើ ធ្លុងតែមួយជាមួយសង្គមរបស់យើង ដើម្បីឲ្យសង្គមរបស់យើងរកឃើញពន្លឺនៃមេត្តាករុណា តាមរយៈសេចក្ដីស្រឡាញ់ និងតាមរយៈអំណរសប្បាយ ដែលយើងចែករំលែកនៅក្នុងជីវិតរបស់យើងជាប្រចាំ។ អាម៉ែន។